ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

កិច្ចព្រមព្រៀង

ស្តីពីការព្យួរកិច្ចសន្យាការងារជូនកម្មករនិយោជិត

ឆ្នាំពីរពាន់ម្ភៃបួន ថ្ងៃទីដប់បី ខែមករា វេលាម៉ោងប្រាំបី និងសាមសិបនាទី នៅការិយាល័យក្រុមហ៊ុនតាកែវស៊ូ (ខេមបូឌា) ដែលមានទីតាំងស្ថិតនៅភូមិត្រាំ សង្កាត់រកាក្រៅ ក្រុងដូនកែវ ខេត្តតាកែវ មានបើកកិច្ចប្រជុំរួមស្តីពីការព្យួរកិច្ចសន្យាការងារជូនកម្មករនិយោជិត ក្រោមអធិបតីភាពលោកស្រី CHEN CHUNXIA ជានាយកគ្រប់គ្រងរោងចក្រតាកែវស៊ូ (ខេមបូឌា) និងមានការចូលរួមពីអ្នកបកប្រែភាសាចិនខ្មែរ ផ្នែករដ្ឋបាល ផ្នែកគណនេយ្យ ផ្នែកសិទ្ធិមនុស្ស តំណាងសហជីពមូលដ្ឋាន ប្រតិភូបុគ្គលិក និងប្រធានផ្នែកសង្វាក់ផលិតកម្មគ្រប់ផ្នែកទាំងអស់ចំនួន១៥នាក់។

ក/សមាសភាពចូលរួម ៖ បញ្ជីវត្តមានជូនភ្ជាប់។

ខ/របៀបវារៈ ៖ ការព្យួរកិច្ចសន្យាការងារជូនកម្មករនិយោជិត

គ/អំពីលទ្ធផលនៃអង្គប្រជុំ ៖ ក្រោយពីមានការពិភាក្សាគ្នាយ៉ាងល្អិតល្អន់រួចមក ភាគីទាំងពីរបានឯកភាពគ្នា និងសម្រេចព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន១១០នាក់ (ស្រី១១០នាក់) ចាប់ពីថ្ងៃទី២២ ខែមករា ឆ្នាំ២០២៤ រហូតដល់ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៤ មានលក្ខខណ្ឌដូចខាងក្រោម ៖

ចំណុចទី១ ៖ ក្នុងកំឡុងពេលព្យួរការងារ ចាប់ពីថ្ងៃទី២២ ខែមករា ឆ្នាំ២០២៤ រហូតដល់ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៤ ក្រុមហ៊ុននឹងផ្តល់ប្រាក់ឧបត្ថម្ភកំឡុងពេលព្យួរការងារជូនកម្មករនិយោជិតចំនួន ៣៥ដុល្លារ (សាមសិបប្រាំដុល្លារ)។

ចំណុចទី២ ៖ ក្នុងកំឡុងពេលព្យួរការងារ ចាប់ពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២៤ រហូតដល់ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៤ ក្រុមហ៊ុននឹងផ្តល់ប្រាក់ឧបត្ថម្ភកំឡុងពេលព្យួរការងារជូនកម្មករនិយោជិតចំនួន ៧០ដុល្លារ (ចិតសិបដុល្លារ)។

បើកប្រាក់នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២៤ និងនៅខែបន្ទាប់នៅថ្ងៃទី ១០ ខែមីនា ឆ្នាំ២០២៤ ។

ចំណុចទី៣ ៖ កិច្ចព្រមព្រៀងនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៤ នេះតទៅ រហូតដល់មានកិច្ចព្រមព្រៀងថ្មីទៀតមកជំនួស។

អង្គប្រជុំនេះបានបញ្ចប់សព្វគ្រប់នៅវេលាម៉ោង១០ និង១០នាទីព្រឹក នាថ្ងៃខែឆ្នាំដដែល ដោយក្តីសោមនស្សរីករាយ ក្រោមបរិយាកាសយោគយល់ និងអធ្យាស្រ័យគ្នាទៅវិញទៅមក។

ថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៤

បានឃើញ និងឯកភាព	អ្នកធ្វើកំណត់ហេតុ
ប្រធានអង្គប្រជុំ	**ហត្ថលេខា**
ផ្នែករដ្ឋបាល TAKEO SHOES (Cambodia) Co., Ltd — Chen Chunxia	

Scanned with CamScanner